ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខៈ ០៥៥......សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមករា ឆ្នាំ ២០០៩

# ប្រកាស

## ស្តីពី

## ការបន្ថែមសមាសភាពនៃគណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតគណៈកម្មាធិការសម្រាប់គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ បក ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ឆ្នាំ ២០០៦-២០១៥ ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានៅថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៧

- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ៨៦៩ សហវ.ប្រក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ។

## **ស ម្រេ ច**

**ប្រការ ១.-** ត្រូវបានបន្ថែមតំណាង **គណៈកម្មការមូលបត្រកម្ពុជា** ចូលរួមក្នុង «**គណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ**» ដូចមានខាងក្រោម ÷

| | | |
|---|---|---|
| ១. ឯកឧត្តម **ម៉ិញ ឆានក្ញុសល** | អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា | ជាសមាជិក |
| ២. ឯកឧត្តម **កៅ ថាច** | អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា | ជាសមាជិក |

**ប្រការ ២.-** ត្រូវបានបន្ថែមតំណាង **គណៈកម្មការមូលបត្រកម្ពុជា** ចូលរួមក្នុង «**ក្រុមការងារបច្ចេកទេស**» ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **កៅ ថាច** | អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា | ជាអនុប្រធាន |
| ២. លោក **ចន ណារិទ្ធ** | ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នៃគណៈកម្មការមូលបត្រកម្ពុជា | ជាសមាជិក |
| ៣. លោក **សុខ ដារ៉ា** | ប្រធាននាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ នៃគណៈកម្មការមូលបត្រកម្ពុជា | ជាសមាជិក |
| ៤. លោក **ឈុន សម្បត្តិ** | ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ នៃគណៈកម្មការមូលបត្រកម្ពុជា | ជាសមាជិក |

**ប្រការ ៣.-** ប្រធាននៃគណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងប្រធាននៃក្រុមការងារបច្ចេកទេស អគ្គលេខាធិការ នាយកខុទ្ទកាល័យ គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគណៈកម្មការមូលបត្រកម្ពុជា ព្រមទាំងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចប្រការ ០១ និង ០២ ត្រូវទទួលអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា

ប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**គាត ឈន់**

<u>**ចំលងជូន:**</u>

**ដើម្បីជូនជ្រាបៈ**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ធនាគារជាតិនៃកម្ពុជា
- គណៈកម្មការមូលបត្រកម្ពុជា

**ដើម្បីអនុវត្តៈ**
- ដូចប្រការ ៣
- ស្ថាប័នពាក់ព័ន្ធ
- ឯកសារ- កាលប្បវត្តិ